ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី
លេខ : ៣៣ ប.ស.ព

សេចក្តីប្រកាសព័ត៌មាន
ស្តីពី
លទ្ធផលនៃសម័យប្រជុំគណៈអចិន្ត្រៃយ៍គណៈរដ្ឋមន្ត្រី
ថ្ងៃអង្គារ ៨កើត ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
ត្រូវនឹងថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២០

នៅព្រឹកថ្ងៃអង្គារ ៨កើត ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២០ វេលាម៉ោង៨និង៣០នាទីព្រឹក នៅវិមានសន្តិភាព នៃទីស្តីការគណៈរដ្ឋមន្ត្រី មានបើកកិច្ចប្រជុំគណៈអចិន្ត្រៃយ៍គណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុត **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិនិត្យនិងពិភាក្សាលើ៖

១-សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងប្រទេសជាតិស្ថិតក្នុងភាពអាសន្ន។
២-បញ្ហាផ្សេងៗ។

ក្រោយពីបានស្តាប់របាយការណ៍ និងមតិពិភាក្សាផ្លាស់ប្តូរយោបល់រួចមក អង្គប្រជុំគណៈអចិន្ត្រៃយ៍គណៈរដ្ឋមន្ត្រី បានសម្រេចអនុម័ត៖

១-សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងប្រទេសជាតិស្ថិតក្នុងភាពអាសន្ន

សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងប្រទេសជាតិស្ថិតក្នុងភាពអាសន្ន ត្រូវបានរៀបចំឡើងដោយផ្អែកតាមស្មារតីនៃមាត្រា២២ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលចែងថា "នៅពេលប្រជាជាតិប្រឈមមុខនឹងគ្រោះថ្នាក់ ព្រះមហាក្សត្រទ្រង់ប្រកាសប្រទានដំណឹងជាសាធារណៈ ដាក់ប្រទេសជាតិស្ថិតក្នុងភាពអាសន្ន ក្រោយពីបានមតិឯកភាពពីនាយករដ្ឋមន្ត្រី ប្រធានរដ្ឋសភា និងប្រធានព្រឹទ្ធសភា"។

សេចក្តីព្រាងច្បាប់នេះ នឹងផ្តល់ជាមូលដ្ឋានគតិយុត្តដើម្បីធានាដល់ការអនុវត្តមាត្រា២២ថ្មី នៃរដ្ឋធម្មនុញ្ញ និងជាមូលដ្ឋានគតិយុត្តកំណត់សិទ្ធិអំណាចរបស់រាជរដ្ឋាភិបាល ក្នុងការដាក់ចេញនូវវិធានការចាំបាច់ដែលមិនអាចខ្វះបាន ដើម្បីឆ្លើយតបទៅនឹងស្ថានភាពរបស់ប្រទេសជាតិក្នុងភាពអាសន្ន សំដៅការពារសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ ការពារអាយុជីវិតនិងសុខភាពរបស់ប្រជាពលរដ្ឋ ព្រមទាំងការពារទ្រព្យសម្បត្តិ និងបរិស្ថាន។

សេចក្តីព្រាងច្បាប់នេះ នឹងកំណត់នូវបែបបទ នីតិវិធី និងលក្ខខណ្ឌនៃការប្រកាសដាក់ប្រទេសជាតិស្ថិតក្នុងភាពអាសន្ន ព្រមទាំងវិធានការចាំបាច់នានាដែលរាជរដ្ឋាភិបាលមានសិទ្ធិដាក់ចេញក្នុងពេលប្រទេសជាតិស្ថិតក្នុងភាពអាសន្ន។ ការដាក់ប្រទេសជាតិស្ថិតក្នុងភាពអាសន្ន អាចធ្វើឡើងនៅពេលប្រជាជាតិ

ប្រឈមមុខនឹងគ្រោះថ្នាក់ ជាអាទិ៍ គ្រោះថ្នាក់ដែលបង្កឡើងដោយសង្គ្រាមឬការឈ្លានពានពីកម្លាំងបរទេស គ្រោះអាសន្នបន្ទាន់ចំពោះសុខភាពសាធារណៈបណ្តាលមកពីការឆ្លងរាលដាលនៃជំងឺ ភាពវឹកវរធ្ងន់ធ្ងរដល់សន្តិសុខជាតិ និងសណ្តាប់ធ្នាប់សាធារណៈ ព្រមទាំងគ្រោះមហន្តរាយធ្ងន់ធ្ងរ ដែលគំរាមកំហែង ឬអាចបង្កគ្រោះថ្នាក់រីករាលដាលដល់កម្រិតទូទាំងប្រទេស។

សេចក្តីព្រាងច្បាប់នេះ នឹងត្រូវបញ្ជូនទៅសុំការអនុម័តពីស្ថាប័ននីតិប្បញ្ញត្តិតែម្តង ដោយមិនដាក់ឆ្លងកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីទៀតទេ។

២-បញ្ហាផ្សេងៗ

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានលើកឡើងថា៖

១-**រាជរដ្ឋាភិបាល** បានសម្រេចដាក់ចេញនូវវិធានការផ្អាកជាបណ្តោះអាសន្ននូវការនាំចេញស្រូវ និងអង្ករទៅក្រៅប្រទេស លើកលែងអង្ករក្រអូប ដើម្បីត្រៀមស្បៀងបម្រុងទុកសម្រាប់តម្រូវការនៅក្នុងស្រុកឱ្យបានគ្រប់គ្រាន់ សំដៅធានាបរិមាណសន្តិសុខស្បៀង និងស្ថិរភាពថ្លៃអង្ករនៅកម្ពុជា។

២-**រាជរដ្ឋាភិបាល** បានចាត់ទុកអាល់កុល និងម៉ាស់ជាទំនិញយុទ្ធសាស្ត្រ សម្រាប់បម្រុងទុកប្រើប្រាស់ក្នុងកាលៈទេសៈនៃការរីករាលដាលនៃវីរុសកូវីដ-១៩។ រាជរដ្ឋាភិបាលបានសម្រេចបញ្ជាទិញម៉ាស់ ចំនួន ៥លាន ២សែន ក្នុងនោះ ពីក្រៅប្រទេសមានចំនួន ៤លាន និង ពីរោងចក្រផលិតម៉ាស់នៅខេត្តព្រះសីហនុ ចំនួន ១លាន ២សែន ដើម្បីត្រៀមចែកជូនប្រជាពលរដ្ឋ និងផ្តល់ជូនមន្ទីរពេទ្យមួយចំនួន។ ជាងនេះទៅទៀត ក្រៅពីសំលៀកបំពាក់ពេទ្យដែលត្រូវបានផលិតនៅខេត្តស្វាយរៀង រាជរដ្ឋាភិបាលក៏បានបញ្ជាទិញម៉ាស់សម្រាប់គ្រូពេទ្យចំនួនជាង ២០ម៉ឺន បន្ថែមទៀត ដើម្បីបម្រើឱ្យសេចក្តីត្រូវការខាងផ្នែកវេជ្ជសាស្ត្រនាពេលខាងមុខ។ រាជរដ្ឋាភិបាលមានគោលដៅប្រែក្លាយរោងចក្រមួយចំនួនទៅជាផលិតម៉ាស់ អាល់កុល និងសម្ភារៈបរិក្ខារវេជ្ជសាស្ត្រសម្រាប់ផ្គត់ផ្គង់ទៅឱ្យរដ្ឋ ដើម្បីប្រើប្រាស់នៅក្នុងស្រុកតែម្តង។

៣-**សម្តេចតេជោនាយករដ្ឋមន្ត្រី** បានបញ្ជាក់សាជាថ្មីម្តងទៀតថា ជំនួយឧបត្ថម្ភពីសប្បុរសជននឹងមិនត្រូវយកមកផ្គត់ផ្គង់បុគ្គលិកសុខាភិបាលឡើយ តែត្រូវយកទៅទិញសម្ភារៈបរិក្ខារផ្សេងៗ ជាអាទិ៍ ម៉ាស់ និងអាល់កុល សម្រាប់ចែកជូនប្រជាជនវិញ។

៤- **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានក្រើនរំលឹកដល់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងប្រព័ន្ធផ្សព្វផ្សាយទាំងអស់ឱ្យបន្តជួយផ្សព្វផ្សាយសារអប់រំស្តីពីការការពារជំងឺបង្កដោយវីរុសកូវីដ-១៩។ សម្តេចតេជោនាយករដ្ឋមន្ត្រី បានណែនាំជាថ្មីម្តងទៀតឱ្យអាជ្ញាធរពាក់ព័ន្ធគ្រប់លំដាប់ថ្នាក់ទាំងអស់ ជាពិសេសអាជ្ញាធរមូលដ្ឋាន ត្រូវតែគ្រប់គ្រងឱ្យបានម៉ត់ចត់ និងបន្តតាមដានស្ថានភាពសុខភាពរបស់ពលករខ្មែរទាំងឡាយដែលទើបមកពីបរទេស។

៥- **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានផ្តល់អនុសាសន៍ឱ្យត្រៀមទុកនូវវិធានការសេដ្ឋកិច្ចដែលផលប៉ះពាល់ជាសាកលដោយជំងឺបង្កដោយវីរុសកូវីដ-១៩ អាចអូសបន្លាយរយៈពេលយូរ គឺត្រូវពង្រឹងវិស័យកសិកម្មដែលជាចំណុចខ្លាំងរបស់កម្ពុជា ជាពិសេស ការត្រៀមទំនិញស្បៀងចាំបាច់សម្រាប់ប្រជាជនកម្ពុជា ដូចជា អង្ករ និងអំបិល។

អង្គប្រជុំគណៈអចិន្ត្រៃយ៍គណៈរដ្ឋមន្ត្រី បានបិទសម័យប្រជុំនៅវេលាម៉ោង១១ និង១៥ នាទី។

ថ្ងៃអង្គារ ៨កើត ខែចេត្រ ឆ្នាំកុរឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២០